# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៥៦០ .សហវ.អលសា

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០១៧

**គោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**កម្មវត្ថុ** ករណីសំណើសុំពិនិត្យ សម្រេចប្រគល់កិច្ចសន្យា ស្ដីពីការងារជួសជុលចាក់បេតុងឆ្អឹងដែកកម្រាស់ ២០ស.ម ផ្លូវទំនប់កប់ស្រូវជំហានទី១ ជូនរដ្ឋបាលរាជធានីភ្នំពេញ ។

**យោង** - លិខិតលេខ ០០៥ លស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ របស់សាលារាជធានីភ្នំពេញ
- លិខិតលេខ ៤៨៩ សហវ.អលសា ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កំណត់ហេតុចរចាថ្លៃ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ របស់គណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ
- ទិដ្ឋាការធានាចំណាយថវិកាលេខ ០០៥, លេខ០០៦ និងលេខ០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់អភិបាលហិរញ្ញវត្ថុរាជធានីភ្នំពេញ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយល់ព្រមតាមសំណើរបស់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងការប្រគល់កិច្ចសន្យាជូនមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ ដើម្បីធ្វើការងារជួសជុលចាក់បេតុងឆ្អឹងដែកកម្រាស់ ២០ស.ម ផ្លូវទំនប់កប់ស្រូវជំហានទី១ បណ្ដោយ ១២.៧៥៩ម៉ែត្រ ទទឹង ៩,៧៥ម៉ែត្រ ផ្ទៃក្រឡា ១២៤.៤០០ម៉ែត្រការ៉េ ដាក់លូមូលទំហំ ១,៥ម៉ែត្រ កាត់ទទឹងផ្លូវ ២កន្លែង ចាក់ដីសពង្រីកតួផ្លូវបណ្ដោយ ១២.៧៥៩ម៉ែត្រ ទទឹង ១២ម៉ែត្រ ផ្ទៃក្រឡា ១៥៣.១០៨ម៉ែត្រការ៉េ រៀបសួនច្បារកណ្ដាលទ្រូងផ្លូវ ទទឹង ២,៥ម៉ែត្រ បណ្ដោយ ១២.៧៥៩ម៉ែត្រ និងតម្លើងបង្គោលភ្លើងព្រែកចំនួន ៤២៥ដើម ចាប់ពីផ្លូវរថភ្លើង ដល់រង្វង់មូលស្ពានព្រែកព្នៅ ក្នុងខណ្ឌពោធិ៍សែនជ័យ និងខណ្ឌព្រែកព្នៅ ដែលមានទឹកប្រាក់សរុបចំនួន ៥៨.០៣៤.០០០.០០០រៀល (ហាសិបប្រាំបីប៊ីលាន សាមសិបបួនលានរៀលគត់) ជាតម្លៃកិច្ចសន្យា ។

ការជួលបន្តទៅឲ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ដាច់ខាត ។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបាន ត្រូវដកហូតប្រគល់ឲ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ ។ ក្នុងករណីប្រគល់ឲ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តម មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន៖**
- *មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ*
- *មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ*
- *ឯកសារ-កាលប្បវត្តិ*



Scanned by CamScanner